# បច្ចុប្បន្នភាពយុទ្ធសាស្ត្រការពារជាតិ

# DEFENCE STRATEGIC UPDATE

# 2024

ក្រុមការងារសៀវភៅសការពារជាតិ

DEFENCE WHITE PAPER WORKING GROUP

# កម្រងឯកត

# ការវាយតម្លៃយុទ្ធសាស្ត្រ

# និងការផ្តល់យោបល់

ដោយក្រុមការងារសៀវភៅសការពារជាតិ

ខែធ្នូ ឆ្នាំ២០២៤

# អារម្ភកថា

សៀវភៅសការពារជាតិឆ្នាំ២០២២ នៃព្រះរាជាណាចក្រកម្ពុជា លាតត្រដាងនូវគោលនយោបាយយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យការពារជាតិរហូតដល់ឆ្នាំ២០៣០។ គោលនយោបាយនេះ កំណត់គោលដៅនៃកិច្ចការពារជាតិ (Defence Objectives) និងអាទិភាពជាយុទ្ធសាស្ត្រ (Strategic Priorities) បួនយ៉ាង រួមមាន៖ កិច្ចការពារព្រំដែន សន្តិសុខផ្ទៃក្នុង កំណែទម្រង់យោធា និងកិច្ចសហប្រតិបត្តិការយោធាអន្តរជាតិ។ លើសពីនេះទៀត សៀវភៅសការពារជាតិឆ្នាំ២០២២ ផ្តល់អនុសាសន៍សំខាន់ៗមួយចំនួន សម្រាប់ជំរុញការអនុវត្តគោលនយោបាយការពារជាតិ ឱ្យទទួលបានលទ្ធផលជាវិជ្ជមាន និងប្រកបដោយផ្លែផ្កា។

តែទោះជាដូច្នេះក្តី ការវិវត្តឥតឈប់ឈរនៃសភាពការណ៍សន្តិសុខនៅក្នុងតំបន់ និងលើពិភពលោក ព្រមទាំងការបត់បែនណាមួយក្នុងវិធានការយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទីមួយរបស់រាជរដ្ឋាភិបាល រមែងមានឥទ្ធិពលគ្របដណ្តប់មកលើគោលនយោបាយ និងយុទ្ធសាស្ត្ររបស់វិស័យការពារជាតិជានិច្ច។

ការចងក្រងនូវឯកសារ "បច្ចុប្បន្នភាពយុទ្ធសាស្ត្រការពារជាតិ" (Defence Strategic Update) មានគោលបំណង៖

- លើកស្ទួយសមត្ថភាពផ្នែកស្រាវជ្រាវ វិភាគវាយតម្លៃ និងការបង្កើតគោលនយោបាយយុទ្ធសាស្ត្រ នៅក្នុងចំណោមនាយទាហាន និងអ្នកយុទ្ធសាស្ត្រជំនាន់ក្រោយ
- វិភាគ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពសភាពការណ៍ លើវិស័យសន្តិសុខ និងវិស័យការពារជាតិ ក្នុងលំដាប់យុទ្ធសាស្ត្រ
- ផ្តល់អនុសាសន៍ជាគន្លឹះជូនថ្នាក់ដឹកនាំ សម្រាប់ជាជំនួយស្មារតីនៅក្នុងការដឹកនាំ និងការធ្វើសេចក្តីសម្រេចចិត្ត
- ផ្តល់ធាតុចូលដែលចាំបាច់ សម្រាប់ការធ្វើវិវេចនា ឬការរៀបចំគោលនយោបាយ ក្នុងវិស័យការពារជាតិ។

បច្ចុប្បន្នភាពយុទ្ធសាស្ត្រការពារជាតិ ពុំមែនជាឯកសារឆ្លុះបញ្ចាំងអំពីការផ្លាស់ប្តូរគោលនយោបាយ ឬជាការធ្វើវិវេចនាលើគោលនយោបាយ

ក្នុងវិស័យការពារជាតិនោះទេ។ ផ្ទុយទៅវិញ គឺជាការវិភាគ វាយតម្លៃ និងផ្តល់គំនិតយោបល់បន្ថែមស្របតាមការវិវត្តថ្មីៗក្នុងព្រះរាជាណាចក្រកម្ពុជា តំបន់ និងពិភពលោក ដោយក្រុមស្រាវជ្រាវគោលនយោបាយយុទ្ធសាស្ត្រ (Strategic Policy Group) ដែលជាសេនាធិការរបស់ក្រុមការងារសៀវភៅសការពារជាតិ។ ដូច្នេះ មានន័យថា សៀវភៅសការពារជាតិ (Defence White Paper) និងឯកសារវិវេចនាយុទ្ធសាស្ត្រការពារជាតិ (Defence Strategic Review) នៅតែជាឯកសារគោលនៅក្នុងការកំណត់គោលនយោបាយ ឬការប្រកាន់យកភាពបត់បែននៃគោលនយោបាយលើវិស័យការពារជាតិដដែល។ ឯកសារបច្ចុប្បន្នភាពយុទ្ធសាស្ត្រការពារជាតិ នឹងត្រូវរៀបចំនៅរាល់ពីរឆ្នាំម្តង ជាពិសេសនៅចន្លោះការផលិតសៀវភៅសការពារជាតិ និងឯកសារវិវេចនាយុទ្ធសាស្ត្រការពារជាតិ។ បច្ចុប្បន្នភាពយុទ្ធសាស្ត្រការពារជាតិលើកទី២ នឹងចេញផ្សាយនៅចុងឆ្នាំ២០២៦ ហើយអាចនឹងក្លាយជាឯកសារផ្លូវការរបស់ក្រសួងការពារជាតិតាមការចាំបាច់។

**ក្រុមការងារសៀវភៅសការពារជាតិ**

# សេចក្តីផ្តើម

ក្នុងនាមជាប្រជាជាតិមួយ ដែលមានប្រវត្តិដ៏យូរលង់រាប់ពាន់ឆ្នាំ ធ្លាប់ឆ្លងកាត់ជាច្រើនដំណាក់កាល ទាំងក្នុងយុគសម័យអាណាចក្ររុងរឿង ទាំងក្នុងស្ថានភាពហិនហោចខ្លោចផ្សារស្ទើរតែបាត់បង់អត្តសញ្ញាណ កំពុងងើបឡើងប្រកបដោយសក្តានុពល ក្រោមសន្តិភាព និងការឯកភាពជាតិពេញលេញ ដែលមិនធ្លាប់មាននៅក្នុងរយៈពេលជាច្រើនទសវត្ស ក្រោមការដឹកនាំដ៏អង់អាច និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងបន្តវេណដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**។

ពិតណាស់ ការដឹកនាំប្រកបដោយជោគជ័យ និងមានការទទួលខុសត្រូវយ៉ាងធំធេងចំពោះមុខប្រវត្តិសាស្ត្រ មិនត្រឹមតែកើតមានបានដោយសារលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់អ្នកដឹកនាំប៉ុណ្ណោះទេ តែពឹងផ្អែកជាចម្បងផងដែរលើប្រព័ន្ធការងារប្រទាក់ក្រឡាការវិភាគ វាយតម្លៃសភាពការណ៍បានច្បាស់លាស់ និងការដាក់ចេញនូវវិធានការបានចំគោលដៅ។

រឿងរ៉ាវនៅជុំវិញពិភពលោកមានការវិវត្តឥតឈប់ឈរ ទាំងក្នុងភាពវិជ្ជមាន និងអវិជ្ជមាន។ សង្គ្រាម និងកោលាហល ដែលកើតឡើង ទោះស្ថិតនៅជិតក្តី ឆ្ងាយក្តី ព្រមទាំងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងការប្រឈមដាក់គ្នាឥតឈប់ឈរ រវាងមហាអំណាច រមែងជះឥទ្ធិពលមកលើសន្តិភាព និងសន្តិសុខរបស់ប្រទេសកម្ពុជាជានិច្ច។ នៅគ្រប់កាលៈទេសៈកម្ពុជាចាត់ទុកសន្តិភាព និងសន្តិសុខ ជាមូលដ្ឋានស្លាប់រស់ សម្រាប់ការរស់រាន អត្តសញ្ញាណ ភាពសុខដុមរមនា និងវិបុលភាព របស់ប្រទេសជាតិ។ យើងជឿជាក់លើគោលជំហរអព្យាក្រឹត្យ មិនប្រកាន់បក្សសម្ព័ន្ធ និងការដោះស្រាយបញ្ហាដោយការអត់ធ្មត់ ដោយសន្តិវិធី គោរពផលប្រយោជន៍ និងសម្បទានគ្នាទៅវិញទៅមក ឈរលើស្មារតីឈ្នះ ឈ្នះ។

គោលដៅនៃកិច្ចការពារជាតិរបស់កម្ពុជារហូតដល់ឆ្នាំ២០៣០ ផ្តោតលើការថែរក្សាឱ្យបានគង់វង្សនូវសន្តិភាព ការពាររាល់ផលប្រយោជន៍ជាតិ និងបង្កើនកិច្ចសហប្រតិបត្តិការផ្នែកយោធានៅលើឆាកអន្តរជាតិ។ ដើម្បីសម្រេចបាននូវគោលដៅនេះ កិច្ចការជាយុទ្ធសាស្ត្រមួយចំនួនត្រូវបានចាត់ទុកជាអាទិភាព។ ទោះជាដូច្នេះក្តី ឥទ្ធិពលនៃវិបត្តិក្នុងតំបន់ និងនៅលើ

ពិភពលោក ពិតជាបង្កឱ្យមានការបារម្ភចំពោះផលប៉ះពាល់អវិជ្ជមាន មកលើសន្តិសុខ ស្ថិរភាពនយោបាយ អធិបតេយ្យ និងការអភិវឌ្ឍសេដ្ឋកិច្ច របស់ប្រទេសកម្ពុជា ជាដរាប។ ទន្ទឹមនឹងនេះ ស្ថិរភាពនយោបាយ និងសន្តិសុខផ្ទៃក្នុង គឺជាកត្តាសំខាន់បំផុត នៅក្នុងការការពារភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ ពង្រឹងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរក្សានិរន្តរភាពនៃការអភិវឌ្ឍជាតិ។

ដូច្នេះ កម្ពុជាគប្បីពិនិត្យតាមដានរាល់ការវិវត្តិទាំងនោះយ៉ាងហ្មត់ចត់ទាំងនៅខាងក្នុង ទាំងនៅខាងក្រៅប្រទេស ដើម្បីកំណត់គោលជំហរឱ្យបានសមស្រប និងចាត់វិធានការឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។

# ការងើបឡើងវិញនៃការគំរាមកំហែង ផ្នែកសន្តិសុខជាប្រពៃណី

## ទិដ្ឋភាពភូមិសាស្ត្រនយោបាយ

ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយដ៏ស្រួចស្រាវ និងនិន្នាការពហុប៉ូល កំពុងវិវត្តក្នុងកំសួលខ្លាំងជាងក្នុងយុគសម័យសង្គ្រាមត្រជាក់ទៅទៀត។ ពិភពលោកហាក់បាត់បង់នូវតម្លៃនៃសណ្តាប់ធ្នាប់ ដែលផ្អែកលើច្បាប់អន្តរជាតិ ហើយការគំរាមកំហែងផ្នែកសន្តិសុខជាប្រពៃណី បានបង្ហាញខ្លួនឡើងវិញនៅតំបន់អឺរ៉ុប មជ្ឈឹមបូព៌ា អាស៊ីប៉ាស៊ីហ្វិក និងតំបន់អាហ្វ្រិក។ ការគ្រប់គ្រងទំនាស់ និងជម្លោះទាំងឡាយតាមបែបហឹង្សា និងការសងសឹកគ្នាទៅវិញទៅមក ត្រូវបានយកមកប្រើ គួបផ្សំជាមួយការជ្រៀតជ្រែកពីខាងក្រៅ។ សូចនាករនៃសង្គ្រាមលោក ឬសង្គ្រាមតំបន់ កាន់តែមានច្រើនឡើង ហើយពិភពលោកកំពុងស្ថិតក្រោមការគំរាមកំហែងនៃការប្រើប្រាស់អាវុធនុយក្លេអ៊ែរ ជាងពេលណាទាំងអស់។ ការបាត់បង់សណ្តាប់ធ្នាប់នឹងបន្តអូសបន្លាយ ដោយសារការដណ្តើមឧត្តមភាពផ្នែកសេដ្ឋកិច្ចតាមរយៈការវិលត្រឡប់នូវសង្គ្រាមពាណិជ្ជកម្ម និន្នាការគាំពារនិយម ការគំរាមអំពីការកើតឡើងនៃសង្គ្រាមលោក ការប្រណាំងប្រជែងសព្វាវុធ និងកំណើននៃការប្រើប្រាស់កងទ័ពស៊ីឈ្នួល។

## សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន

រហូតមកដល់បច្ចុប្បន្ននេះ ពុំមានសញ្ញាណាមួយបង្ហាញឱ្យឃើញអំពីលទ្ធភាព នៃការបញ្ចប់សង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ឱ្យបានឆាប់នៅឡើយទេ។ ការដណ្តើមកាន់កាប់ទឹកដីដោយភាគីទាំងសងខាងនៅមានសន្ទុះខ្លាំងនៅឡើយ ហើយរុស្ស៊ី និងអ៊ុយក្រែន កំពុងព្យាយាមអូសទាញប្រទេសដទៃទៀត ឱ្យចូលរួមពាក់ព័ន្ធក្នុងជម្លោះនេះ។ ផែនការជ័យជំនះរបស់លោកហ្សេលែនស្គី (Zelensky) ដែលមានទំនោរនាំយកអង្គការណាតូមកពាក់ព័ន្ធ វត្តមានរបស់កងទ័ពកូរ៉េខាងជើងនៅលើទឹកដីរុស្ស៊ី គោលលទ្ធិថ្មីរបស់រុស្ស៊ី

អំពីការប្រើប្រាស់អាវុធនុយក្លេអ៊ែរ និងការអនុញ្ញាតឱ្យអ៊ុយក្រែនបាញ់កាំជ្រួចដែលផ្តល់ដោយសហរដ្ឋអាមេរិកចូលទឹកដីរុស្ស៊ី បានធ្វើឱ្យស្ថានការណ៍កាន់តែធ្ងន់ធ្ងរឡើងរួមទាំងលទ្ធភាពនៃការកើតសង្គ្រាមលោក ទៀតផង។ ការប្តេជ្ញាផ្តល់អាវុធរបស់កូរ៉េខាងត្បូងទៅឱ្យអ៊ុយក្រែន ដើម្បីឆ្លើយតបទៅនឹងឥរិយាបទរបស់កូរ៉េខាងជើង អាចនឹងបង្កើនភាពតានតឹងនៅក្នុងឧបទ្វីបកូរ៉េផងដែរ។ ទោះជាយ៉ាងណាក៏ដោយ ការអូសបន្លាយសង្គ្រាមនេះ បានធ្វើឱ្យរុស្ស៊ី និងអ៊ុយក្រែន ទទួលរងបញ្ហាប្រឈមជាច្រើនដូចជា សម្ពាធពីសហគមន៍អន្តរជាតិ ការថយចុះចំនួនប្រជាជនយ៉ាងគំហុគ ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ ឱនភាពសេដ្ឋកិច្ច និងការគម្រាមកំហែងសន្តិសុខក្នុងតំបន់ និងអន្តរជាតិ។ រុស្ស៊ីកំពុងត្រូវបានជំរុញដោយបណ្តាប្រទេសដែលជាសមាជិក BRICS ឱ្យឆាប់បញ្ឈប់សង្គ្រាមនៅអ៊ុយក្រែន ហើយងាកមករួមជាមួយប្រទេសក្នុងប្លុក Global South (ក្រុមប្រទេសកំពុង និងមិនទាន់អភិវឌ្ឍ)ដើម្បីកសាងសក្តានុពលផ្នែកសេដ្ឋកិច្ចវិញ។ លើសពីនេះទៀត សង្គ្រាមនៅមជ្ឈិមបូព៌ា និងលទ្ធផលនៃការបោះឆ្នោតនៅសហរដ្ឋអាមេរិក កំពុងធ្វើឱ្យរូបភាពនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនមានការផ្លាស់ប្តូរ។

ថ្វីត្បិតតែមានគោលជំហរជំទាស់ទៅនឹងការប្រើប្រាស់កម្លាំងដណ្តើមទឹកដី នៃរដ្ឋអធិបតេយ្យក៏ដោយ កម្ពុជាចង់ឃើញឱ្យមានកិច្ចប្រឹងប្រែងក្នុងការបញ្ឈប់ការលូកដៃពីខាងក្រៅ ដើម្បីដាក់គំនាបលើភាគីជម្លោះទាំងពីរ ឱ្យបង្ខំចិត្តបញ្ចប់សង្គ្រាមតាមរយៈការចចារ ដោយមានដំណោះស្រាយនយោបាយដ៏ជាក់លាក់មួយ ដែលអាចទទួលយកបានដោយភាគីទាំងសងខាង។ សម្ព័ន្ធមិត្តទាំងសងខាង គួរជំរុញឱ្យប្រទេសទាំងពីរ ប្រឹងប្រែងស្វែងរកការបញ្ចប់សង្គ្រាមដោយខ្លួនឯង ជាជាងការលើកទឹកចិត្តឱ្យបន្តការប្រយុទ្ធ។ មកទល់ពេលនេះ យើងដឹងច្បាស់ថា សង្គ្រាមនេះ ពិតជាមិនអាចបញ្ចប់ដោយសារការប្រើប្រាស់កម្លាំងបានឡើយ ដូចនេះសហគមន៍អន្តរជាតិ គួរខិតខំស្វែងរកវិធីសាស្រ្តបញ្ចប់សង្គ្រាម តាមផ្លូវការទូត។

យោងទៅតាមការឃោសនាបោះឆ្នោតរបស់ប្រធានាធិបតី ដូណាល់ត្រាំ ក្នុងឆ្នាំ២០២៤កន្លងទៅនេះ សហរដ្ឋអាមេរិកទំនងជាប្រកាន់យកឥរិយាបទបង្ខំឱ្យបញ្ចប់សង្គ្រាម តាមរយៈការកាត់បន្ថយជំនួយយោធាដល់អ៊ុយក្រែន។ ទោះជាយ៉ាងណាក៏ដោយ អាមេរិកមុខជានឹងមិនបណ្តោយឱ្យរុស្ស៊ីកេង

ចំណោញ និងមិនចង់ឃើញភាគីណាមួយប្រកាសថាខ្លួនជាអ្នកឈ្នះសង្គ្រាម នោះដែរ។

## វិបត្តិនៅមជ្ឈឹមបូព៌ា

វិបត្តិនៅមជ្ឈឹមបូព៌ា អាចនឹងរីករាលដាលជាបន្តទៅទៀត។ សោកនាដកម្មមនុស្សជាតិនៅមជ្ឈឹមបូព៌ា បានទាញយកចំណាប់អារម្មណ៍ និងភាពអាណិតអាសូរ ពីសំណាក់សហគមន៍អន្តរជាតិ រួមទាំងអង្គការសហប្រជាជាតិផងដែរ។ ការជំរុញឱ្យមានដំណោះស្រាយរដ្ឋពីរ (អ៊ីស្រាអែល និងប៉ាឡេស្ទីន) នៅតែពុំទាន់មានពន្លឺនៅឡើយ។ ការតស៊ូប្រឆាំងនឹងអ៊ីស្រាអែលរបស់ក្រុមហាម៉ាស់ និងហេសបូឡា នឹងមិនងាយបញ្ចប់ ហើយក្រុមប្រឆាំងនឹងអ៊ីស្រាអែលដទៃទៀត នៅតែមានសមត្ថភាពក្នុងការវាយប្រហារមកលើអ៊ីស្រាអែល ដោយមានការគាំទ្រពីអ៊ីរ៉ង់។ កិច្ចប្រឹងប្រែងឱ្យមានបទឈប់បាញ់រវាងអ៊ីស្រាអែល និងក្រុមហេសបូឡា ទំនងជាមិនជាប់លាប់ទេ។ ការសងសឹកគ្នាទៅវិញទៅមក រវាងអ៊ីស្រាអែល និងអ៊ីរ៉ង់ ក៏ទំនងជាមិនទាន់ដល់ទីបញ្ចប់នៅឡើយដែរ។ ដើម្បីការរស់រានរបស់ខ្លួន អ៊ីស្រាអែលចាំបាច់ត្រូវពង្រីកសមរភូមិ ដូច្នេះមធ្យោបាយសម្រាប់ធ្វើសង្គ្រាមមួយផ្នែកធំ ត្រូវពឹងផ្អែកលើសហរដ្ឋអាមេរិក។ ការត្រឡប់មកសារជាថ្មីរបស់លោកប្រធានាធិបតីដូណាល់ ត្រាំ ទំនងជាមិនធ្វើឱ្យមានការប្រែប្រួលច្រើននៅមជ្ឈឹមបូព៌ានោះទេ។

ជាងនេះទៅទៀត ការសម្រេចចេញដីកាចាប់ខ្លួននាយករដ្ឋមន្ត្រីអ៊ីស្រាអែល លោកបេនចាមិន នេតាន់យ៉ាហ៊ូ ដោយតុលាកាឧក្រិដ្ឋកម្មអន្តរជាតិ សិទ្ធិវេតូរបស់សហរដ្ឋអាមេរិកនៅក្នុងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ទស្សនៈរបស់លោកដូណាល់ ត្រាំ ក្នុងរឿងចំណាប់ខ្មាំងនៅក្នុងហ្គាហ្សា និងការទាមទាររបស់អ៊ីរ៉ង់ឱ្យប្រហារជីវិតមេដឹកនាំអ៊ីស្រាអែល នឹងធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងឱ្យមានបទឈប់បាញ់នៅហ្គាហ្សា កាន់តែជួបឧបសគ្គ។ ការគាំទ្ររបស់សហរដ្ឋអាមេរិកចំពោះអ៊ីស្រាអែល នឹងនៅដដែល តែប្រហែលជាជ្រើសរើសយកការបង្រួមទំហំនៃវិបត្តិ ជាពិសេសនៅហ្គាហ្សា និងលីបង់ តែអាចនឹងបង្កើនការកៀបសង្កត់លើអ៊ីរ៉ង់។ ទោះដូច្នេះក្តី អ៊ីស្រាអែលអាចទទួលរ៉ាប់រងការធ្វើសង្គ្រាមដោយខ្លួនឯង ច្រើនជាងមុន។

សភាពការណ៍នៅស៊ីរី បន្ថែមការព្រួយបារម្ភអំពីការរីករាលដាលនៃជម្លោះ។ ក្រៅពីលទ្ធភាពនៃការដួលរលំរបស់រដ្ឋាភិបាលក្រុងដាម៉ាស់ សង្គ្រាមស៊ីវិលដែលឆាបឆេះឡើងវិញមួយនេះ នឹងទាញយកការពាក់ព័ន្ធកាន់តែខ្លាំងឡើង ពីសំណាក់តួអង្គមួយចំនួនដូចជារុស្ស៊ី អ៊ីរ៉ង់ តួកគី ក្រុមហេសបូឡា សហរដ្ឋអាមេរិក និងអ៊ីស្រាអែល។ លទ្ធភាពណាមួយនៃការបញ្ជូនអាវុធ និងសម្ភារសឹក ពីសំណាក់អ៊ីរ៉ង់ និងរុស្ស៊ី ដើម្បីជួយស្រោចស្រង់រដ្ឋាភិបាលលោកបាស់សា អាល់អាសាដ អាចនឹងធ្លាក់ដល់ដៃក្រុមហេសបូឡា ដែលនឹងធ្វើឱ្យអ៊ីស្រាអែលចាំបាច់ត្រូវធ្វើការឆ្លើយតប។ ទន្ទឹមនេះ ការឆក់ឱកាសពង្រីកខ្លួនឡើងវិញរបស់ក្រុមអាយស៊ីសក្នុងប្រទេសស៊ីរី ក៏ជាការបារម្ភមួយទៀតផងដែរ។

ដំណោះស្រាយបញ្ចប់សង្គ្រាមតាមផ្លូវនយោបាយ ពិតជាមិនងាយនឹងសម្រេចបានឡើយ ដរាបណាភាគីទាំងសងខាង នៅតែជ្រើសរើសយកការបំបាត់ និងបំផ្លាញគ្នាទៅវិញទៅមក។ នៅក្នុងបរិបទនេះ ដំណោះស្រាយឱ្យមានរដ្ឋពីរ ពិបាកនឹងសម្រេចបាននៅឡើយ។ ជម្រើសដ៏ប្រសើរ គឺបន្តព្យាយាមជំរុញឱ្យមានបទឈប់បាញ់ដ៏ជាប់លាប់ឱ្យបានឆាប់ ដើម្បីបញ្ឈប់ការបាត់បង់ជីវិតជនស៊ីវិលស្លូតត្រង់ និងវិលទៅរកស្ថានភាពមុនថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៣ វិញ។ បន្ទាប់ពីនោះ ការងារដែលត្រូវធ្វើបន្ទាន់មានដូចជាការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខ្ទេចខ្ទាំ ការស្តារសេដ្ឋកិច្ចដែលដុនដាប លើកកម្ពស់សុខមាលភាព និងការគិតគូរអំពីជោគវាសនានៃជនរងគ្រោះ និងគ្រួសារដែលមានអ្នកបាត់បង់អាយុជីវិត។

## ចំណុចក្តៅនៃកោះតៃវ៉ាន់

បញ្ហាកោះតៃវ៉ាន់ នៅតែជាចំណុចក្តៅ ក្នុងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរបស់ប្រទេសមហាអំណាចចិន និងសហរដ្ឋអាមេរិក។ ទោះមានការប្តេជ្ញាចិត្តខ្ពស់ គួបផ្សំនឹងកម្លាំងយោធាដ៏មហិមារបស់ខ្លួន ចិននៅតែមានសង្ឃឹមថានឹងអាចបង្រួបបង្រួមជាតិតាមផ្លូវនយោបាយ និងការទូត។ លទ្ធភាពនៃការបង្រួបបង្រួមជាតិរបស់ចិន អាចប្រែប្រួលទៅតាមកត្តាមួយចំនួន ដូចជាការផ្លាស់ប្តូរឥរិយាបទរបស់មេដឹកនាំតៃវ៉ាន់នៅថ្ងៃអនាគត គោលជំហររបស់អន្តរជាតិក្នុងការទទួលស្គាល់ចិនតែមួយ គំនាបសង្កត់ដោយអនុភាព

សេដ្ឋកិច្ច និងយោធារបស់ចិន និងការថមថយការគាំទ្រណាមួយរបស់សហរដ្ឋអាមេរិកចំពោះកោះតៃវ៉ាន់។

## ឧបទ្វីបកូរ៉េ

ការបន្ធូរ ឬបង្កើនភាពតានតឹងពីសំណាក់កូរ៉េខាងជើង អាចជាការអូសបន្លាយពេលវេលា និងផ្លាស់ប្តូរប្រធានបទ ដើម្បីផ្តល់ឱកាសសម្រាប់ការកសាងសមត្ថភាពផ្នែកយោធា ជាពិសេស អានុភាពនៃកាំជ្រួចរយៈចម្ងាយឆ្ងាយ និងអាវុធនុយក្លេអ៊ែរ។ ការគាំទ្រ ការការពារពីរុស្ស៊ី និងចិន នៅតែអាចធានាបានថាអំណាចរបស់គ្រួសារលោកគីម ជុងអ៊ុន ខ្លាំងក្លាជាងមុន។ សម្ព័ន្ធមិត្តត្រីភាគី រួមមានរុស្ស៊ី កូរ៉េខាងជើង និងចិន នឹងបង្កើតបានជារនាំងទប់ស្កាត់ឥទ្ធិពលរបស់សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តខ្លួនក្នុងតំបន់។

ម៉្យាងទៀត ការពាក់ព័ន្ធរបស់កូរ៉េខាងជើងនៅក្នុងសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងប្រតិកម្មរបស់កូរ៉េខាងត្បូង និងសម្ព័ន្ធមិត្ត នឹងនាំឱ្យមានការផ្លាស់ប្តូររូបភាពនៃសន្តិសុខនៅអឺរ៉ុប និងអាស៊ីប៉ាស៊ីហ្វិក ឬក៏អាចនាំឱ្យមានសង្គ្រាមនៅឧបទ្វីបកូរ៉េបាន។ កូរ៉េខាងជើងនឹងនៅតែជាកូនអុកយុទ្ធសាស្ត្រដ៏សំខាន់ របស់ចិន និងរុស្ស៊ី ហើយភាពតានតឹងនៅឧបទ្វីបកូរ៉េ នឹងកើនកម្តៅដោយសារតែកង្វះខាតយន្តការសម្របសម្រួល និងស្វែងរកសន្តិភាពដ៏មានប្រសិទ្ធភាព។

ជាមួយនឹងការវិលត្រលប់មកវិញរបស់លោកប្រធានាធិបតីដូណាល់ត្រាំ សហរដ្ឋអាមេរិកមុខជានឹងធ្វើការជាមួយសម្ព័ន្ធមិត្តក្នុងតំបន់ ដើម្បីដាក់សម្ពាធលើមេដឹកនាំកូរ៉េខាងជើង និងស្វែងរកការចរចាជាថ្មី ក្នុងគោលបំណងកាត់បន្ថយការចូលរួមគាំទ្ររបស់កូរ៉េខាងជើងចំពោះរុស្ស៊ី នៅក្នុងសង្គ្រាមជាមួយអ៊ុយក្រែន និងដើម្បីបន្ធូរបន្ថយភាពតានតឹងនៅឧបទ្វីបកូរ៉េតាមរយៈការចរចា និងការផ្តល់ជម្រើសនយោបាយ និងសេដ្ឋកិច្ចដល់កូរ៉េខាងជើង។

## សមុទ្រចិនខាងត្បូង និងខាងកើត

ជាដរាបរៀងមក កម្ពុជាតែងតែចង់ឃើញដំណោះស្រាយវិបត្តិនៅក្នុងសមុទ្រចិនខាងត្បូង និងខាងកើត តាមរយៈការអត់ធ្មត់ជាអតិបរមា ពីសំណាក់ភាគីពាក់ព័ន្ធ ការដោះស្រាយបញ្ហាដោយសន្តិវិធីតាមច្បាប់អន្តរជាតិ និងការរក្សាស្ថានភាពដើម (Status quo)។ លើសពីនេះទៀត កម្ពុជាចង់ឱ្យមានការអនុវត្តពេញលេញនូវសេចក្តីប្រកាសស្តីពីការប្រតិបត្តិនៃភាគីនានានៅសមុទ្រចិនខាងត្បូង (DoC) និងពន្លឿនការបង្កើតក្រមប្រតិបត្តិ (CoC) ឱ្យបានឆាប់។ តាមការសង្កេត ការពឹងផ្អែកលើវិធានការនេះទាំងស្រុងប្រហែលជាមិនគ្រប់គ្រាន់ ដើម្បីទប់ស្កាត់ការរីករាលដាលនៃបញ្ហានោះទេ។ ការប្រឈមមុខដាក់គ្នារវាងប្រទេសចិន និងហ្វីលីពីន ការគាំទ្រផ្នែកយោធាសាជាថ្មីរបស់អាមេរិកចំពោះប្រទេសហ្វីលីពីន ទំនាស់រវាងចិន និងវៀតណាម ព្រមទាំងសូចនាករនៃការចាប់ផ្តើមមានបញ្ហារវាងចិន និងឥណ្ឌូនេស៊ី បានជំរុញឱ្យស្ថានការណ៍ស្ថិតក្នុងស្ថានភាពព្រួយបារម្ភកាន់តែខ្លាំងឡើង។ លើសពីនេះទៀត ការចាក់ដីពង្រីកថ្មប៉ប្រះទឹក បានកំពុងធ្វើឱ្យមានកង្វល់អំពីការប្រេះឆាក្នុងចំណោមប្រទេសសមាជិកអាស៊ានដែលពាក់ព័ន្ធនឹងការទាមទារអធិបតេយ្យដែនសមុទ្រ។ កម្ពុជាយល់ឃើញថា ភាគីពាក់ព័ន្ធទាំងអស់ គួរយកចិត្តទុកដាក់លើឆន្ទៈនៃការដោះស្រាយបញ្ហា ក្នុងទម្រង់ទ្វេភាគី ប្រើប្រាស់មធ្យោបាយការទូតដើម្បីកាត់បន្ថយភាពតានតឹង និងផ្តល់អាទិភាពទៅលើការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ ការពង្រឹងទំនាក់ទំនងការទូតរវាងថ្នាក់ដឹកនាំចិន និងវៀតណាម នៅក្រោយឧបទ្ទវហេតុឆ្នាំសមុទ្រចិន និងទូកនេសាទវៀតណាមក្នុងសមុទ្រចិនខាងត្បូងកន្លងទៅនេះ គឺជាការផ្តល់ឱកាសសម្រាប់ទប់ស្កាត់ការរីករាលដាលនៃជម្លោះ។

## អាស៊ាន និងសន្តិសុខតំបន់

ទាំងអាស៊ាន ទាំងបណ្តាប្រទេសជាដៃគូ ចាត់ទុកតួនាទីរបស់អាស៊ានថាជាយន្តការដ៏សំខាន់បំផុតនៅក្នុងការរក្សាស្ថិរភាព តុល្យភាព និងវិបុលភាពនៅក្នុងតំបន់។ មជ្ឈភាពរបស់អាស៊ានគឺជាគន្លឹះនៅក្នុងការផ្តល់ជាវេទិកាសម្រាប់កិច្ចសន្ទនា និងរួមគ្នាដោះស្រាយបញ្ហាគ្រប់វិស័យ។ ទោះជាដូច្នេះក្តី អាស៊ានកំពុងញាំញីដោយឥទ្ធិពលនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ

វិបត្តិនៅមជ្ឈឹមបូព៌ា ភាពប្រឈមក្នុងសមុទ្រចិនខាងត្បូង និងការកើតឡើងជាបន្តបន្ទាប់នូវយន្តការសន្តិសុខខ្នាតតូច (Minilateralism)។ បណ្ដាប្រទេសសមាជិកអាស៊ានមួយចំនួន ហាក់កំពុងត្រូវបានអូសទាញឱ្យប្រកាន់ជំហរនៅក្នុងការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ។ វិបត្តិនៅប្រទេសមីយ៉ាន់ម៉ាកំពុងបន្តប៉ះពាល់ដល់មុខមាត់ និងជំនឿទុកចិត្តមកលើអាស៊ាន ក្នុងការដោះស្រាយបញ្ហាផ្ទៃក្នុងរបស់ខ្លួន។ នៅក្នុងកិច្ចសហប្រតិបត្តិការលើវិស័យយោធា យន្តការកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន (ADMM) និងកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន-បូក (ADMM-Plus) កំពុងមានវឌ្ឍនភាព ប៉ុន្តែក៏ជួបប្រទះនឹងការលំបាកខ្លះដែរ ដូចជាវិបត្តិនៅមីយ៉ាន់ម៉ា ការវិវត្តនៃយន្តការសន្តិសុខខ្នាតតូចនៅក្នុងតំបន់ ការប្រែប្រួលគោលនយោបាយក្នុង និងក្រៅប្រទេស និងគោលជំហររបស់ប្រទេសជាសមាជិកអាស៊ានមួយចំនួនជាដើម។

អាស៊ានមានការលំបាកនៅក្នុងការបំពេញតួនាទីរបស់ខ្លួន នៅក្រោមគោលការណ៍មជ្ឈភាព (Centrality) និងការមិនជ្រៀតជ្រែក (Non-Interference) ទោះបីជាមានការបត់បែនខ្លះនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ។ ឧទាហរណ៍ជាក់ស្ដែង មានដូចជាការអនុវត្តនូវកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច (Five Points Consensus) ដែលមិនទាន់បានទទួលលទ្ធផលជាវិជ្ជមាននៅឡើយ។ ជាមួយនេះដែរ ក៏សង្កេតឃើញមានការផ្លាស់ប្ដូរគួរឱ្យកត់សម្គាល់មួយចំនួន នៅក្នុងចំណោមប្រទេសជាសមាជិកអាស៊ាន ដូចជាគោលជំហររបស់លោកប្រធានាធិបតីហ្វីលីពីន Ferdinand Marcos Jr. ចំពោះទំនាស់ក្នុងសមុទ្រចិនខាងត្បូង ការឡើងកាន់តំណែងជាប្រធានាធិបតីប្រទេសឥណ្ឌូនេស៊ី របស់លោក Prabowo Subianto ដែលធ្លាប់បរិហារិះគន់យ៉ាងខ្លាំងចំពោះឥទ្ធិពលនៃអនុត្តរភាពនិយម និងអាណានិគមនិយម ព្រមទាំងការចូលរួមរបស់ប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី ថៃ និងវៀតណាម ជាមួយ BRICS ក្នុងឋានៈជាប្រទេសដៃគូ (Partner Country)។ ការប្រែប្រួលទាំងនេះ ក៏ជះឥទ្ធិពលផងដែរ លើការពង្រឹងឯកភាព និងសាមគ្គីភាពរបស់អាស៊ាន តទៅអនាគត។

## ADMM និង ADMM-បូក

ប្រឈមទៅនឹងក្ដីបារម្ភអំពីការថមថយនៃឯកភាពរបស់ខ្លួន អាស៊ាន ត្រូវតែរឹងប៉ឹងទ្វេឡើងទៀតនៅក្នុងការរក្សាអព្យាក្រឹត្យភាព ទប់ទល់នឹងសម្ពាធនៃការប្រកួតប្រជែងរវាងមហាអំណាច និងឥទ្ធិពលនៃនិន្នាការពហុប៉ូល។ នៅក្នុងវិស័យយោធា ADMM និង ADMM-បូក គឺជាយន្ដការដ៏សំខាន់ នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការយោធារវាងបណ្ដាប្រទេសជាសមាជិក និងជាមួយដៃគូសន្ទនាទាំងប្រាំបី។ ចាប់តាំងពីការកកើតនៅឆ្នាំ២០០៦ ADMM បានរៀបចំយុទ្ធសាស្ត្ររយៈពេលវែង ដោយការបង្កើតឯកសារទស្សនទាន (Concept Papers) បានជាច្រើន ជាបន្តបន្ទាប់។ យើងសង្កេតឃើញថា ការអនុវត្តឯកសារទស្សនទានខ្លះ មិនទាន់មានដំណើរទៅមុខជាដុំកំភួន ហើយក៏មានខ្លះទៀតដែលមិនទាន់ត្រូវបានអនុវត្តនៅឡើយ។ យើងចាំបាច់ត្រូវយកចិត្តទុកដាក់ចំពោះបញ្ហានេះ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការប្រកបដោយការអនុវត្តជាក់ស្ដែង (Practical Cooperation) និងតួនាទីនាំមុខរបស់ ADMM សម្រាប់ការឆ្លើយតបទៅនឹងបញ្ហាសន្តិសុខនៅក្នុង និងក្រៅតំបន់។

ក្នុងឋានៈជាស្ថាបនិកមួយនៃការបង្កើត ADMM-បូក កាលពីឆ្នាំ២០១០ យើងបានប្ដេជ្ញាថានឹងប្រើប្រាស់យន្ដការនេះ ដើម្បីប្រែក្លាយចក្ខុវិស័យយុទ្ធសាស្ត្រ (Strategic Vision) ឱ្យទៅជាកិច្ចសហប្រតិបត្តិការប្រកបដោយការអនុវត្តជាក់ស្ដែង។ នៅក្នុងន័យនេះ យើងពិតជាមិនចង់ឃើញដំណើរថយក្រោយនៃយន្ដការ ADMM ឬក៏ ADMM-បូក ដោយគ្រាន់តែជាវេទិកាសម្រាប់ជួបចាប់ដៃ និងសួរសុខទុក្ខគ្នានោះឡើយ។ យើងមិនជំទាស់ដាច់ណាត់ចំពោះគោលបំណងនៃការពង្រីកសមាជិកភាពរបស់ ADMM-បូក នោះទេ តែត្រូវមានការគិតគូរឱ្យបានល្អិតល្អន់ អំពីប្រសិទ្ធភាពនៃតួនាទី និងការទទួលខុសត្រូវ និងអំពីអតុល្យភាពនៃសមាសភាពរបស់ភាគីបូក ដែលបណ្ដាលមកពីការពង្រីកសមាជិកភាពនេះ។ ការកម្រិតត្រឹមផ្ដល់ឋានៈជាអ្នកសង្កេតការណ៍ គឺជាជម្រើសដ៏ប្រសើរមួយ។

## យន្តការសន្តិសុខខ្នាតតូច

កម្ពុជាស្វាគមន៍ចំពោះនិន្នាការនៃការបង្កើត និងពង្រីកយន្តការសន្តិសុខខ្នាតតូច ដែលមានគោលដៅដើម្បីសន្តិភាព ស្ថិរភាព និងកិច្ចសហប្រតិបត្តិការ នៅក្នុងតំបន់ ក៏ប៉ុន្តែយើងក៏មានកង្វល់អំពីបច្ច័យអវិជ្ជមានមួយចំនួន ដែលជំរុញឱ្យមានការប្រកួតប្រជែងកាន់តែខ្លាំងឡើង ធ្វើឱ្យបាត់បង់តុល្យភាពយុទ្ធសាស្ត្រ (Strategic Balance) ក៏ដូចជាគោលបំណងកៀរគរកម្លាំង ដើម្បីប្រឆាំងភាគី ឬប្រទេសណាមួយ។

## វិបត្តិមីយ៉ាន់ម៉ា

យើងយល់ឃើញថា ដំណោះស្រាយសម្រាប់វិបត្តិនៅមីយ៉ាន់ម៉ា គឺពឹងផ្អែកជាចម្បងលើឆន្ទៈនយោបាយរបស់មីយ៉ាន់ម៉ាខ្លួនឯងផ្ទាល់។ មីយ៉ាន់ម៉ាមិនគួរបន្តស្ថិតនៅជាឧបករណ៍បម្រើឱ្យការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច និងសង្គ្រាមស៊ីវិលតទៅទៀតទេ។ គ្រប់ភាគីពាក់ព័ន្ធនៃជម្លោះគួរតែស្វែងរកដំណោះស្រាយតាមគោលការណ៍ឈ្នះ ឈ្នះ ដូចជាការអនុវត្តជាជំណាក់កាលនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច ដើម្បីការរស់រានផ្នែកនយោបាយរបស់ភាគីមីយ៉ាន់ម៉ាដែលពាក់ព័ន្ធទាំងអស់ និងកសាងប្រទេសមីយ៉ាន់ម៉ាប្រកបដោយសន្តិភាព ស្ថិរភាព និងភាពសុខដុមរមនា។ ទោះជាដូច្នេះក្តី នីតិវិធីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិចំពោះមេដឹកនាំយោធាមីយ៉ាន់ម៉ា កំពុងធ្វើឱ្យការអនុវត្តកិច្ចព្រមព្រៀងប្រាំចំណុច ជួបឧបសគ្គកាន់តែខ្លាំងឡើង។

## ប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ

នៅក្នុងរយៈពេលចុងក្រោយនេះ ស្ថានភាពនៃប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ (UNPKO) ជួបប្រទះការលំបាកខ្លាំង។ ប្រទេសនៅទ្វីបអាហ្វ្រិកមួយចំនួនដែលញាំញីដោយអសន្តិសុខ និងសង្គ្រាមស៊ីវិលអស់រយៈពេលជាច្រើនឆ្នាំ បានសម្រេចចិត្តបដិសេធ UNPKO ជាបន្តបន្ទាប់ ដោយសារការអូសបន្លាយពេលវេលា ភាពគ្មានប្រសិទ្ធភាព

ព្រមទាំងអាណត្តិ និងការិយាធិបតេយ្យស្មុគស្មាញរបស់ UNPKO ដែលជាហេតុនាំឱ្យមានការងាកទៅពឹងលើកម្លាំងទាហានស៊ីឈ្នួល (Mercenaries) ពីព្រោះទាហានស៊ីឈ្នួលអាចសម្របតាមការចង់បានរបស់សាមីប្រទេស មានការឆ្លើយតបឆាប់រហ័ស និងមិនមានការត្រួតពិនិត្យពីអន្តរជាតិ។ ការផ្លាស់ប្តូរនេះ ក៏ទទួលឥទ្ធិពលពីការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងការប្រឈមមុខគ្នារវាងរុស្ស៊ី និងប្រទេសមហាអំណាចផ្សេងទៀត។

ការប្រែប្រួលបែបនេះបានជះឥទ្ធិពលដល់ជំនឿទុកចិត្តមកលើ UNPKO និងបណ្តាប្រទេសដែលផ្តល់កម្លាំងរក្សាសន្តិភាព (PKO)។ ឧទាហរណ៍ស្ថានការណ៍នៅលីបង់ បានធ្វើឱ្យកងកម្លាំងបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសលីបង់ (UNIFIL) ទទួលការរំខាននៅក្នុងការបំពេញតួនាទី និងភារកិច្ចចំពោះមុខរបស់ខ្លួន ហើយស្ថិតក្នុងស្ថានភាពការពារសុវត្ថិភាពខ្លួន និងត្រៀមសម្រាប់លទ្ធភាពនៃការចល័ត ដោយសារទទួលរងការគំរាមកំហែងស្ទើររាល់ថ្ងៃពីសំណាក់សង្គ្រាមរវាងអ៊ីស្រាអែល និងក្រុមហេសបូឡា។

នៅទ្វីបអាហ្វ្រិក យើងរំពឹងថា UNPKO នៅតែជាតម្រូវការចាំបាច់នាថ្ងៃអនាគត ហើយប្រទេសទាំងនោះនឹងវិលមករក UNPKO វិញជាមិនខាន ព្រោះថាការប្រើប្រាស់ទាហានស៊ីឈ្នួលមិនធានាបាននូវសន្តិភាពវិជ្ជមាននោះទេ។ ទោះជាដូច្នេះក្តី ការដកចេញ និងការបញ្ជូនចូលទៅវិញរបស់កងកម្លាំងរក្សាសន្តិភាព នឹងនាំឱ្យមានការខាតបង់ច្រើន ទាំងពេលវេលា ការស្តារការគ្រប់គ្រងសភាពការណ៍ សម្ភារៈ និងរចនាសម្ព័ន្ធ ជាដើម។

សរុបរួមមក យើងចង់ឃើញការឯកភាព និងសាមគ្គីភាព ដើម្បីបញ្ចៀសសមរភូមិនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងប្រទេសមហាអំណាច។ យើងស្វាគមន៍ជានិច្ចចំពោះគំនិតផ្តួចផ្តើមទាំងឡាយណាដែលពុំមានគោលដៅប្រកួតប្រជែងគ្នា ប៉ុន្តែជាការបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាពក្នុងតំបន់ ប្រកបដោយការយោគយល់គ្នា និងការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ តំបន់អាស៊ីអាគ្នេយ៍គួរជៀសវាងការធ្វើនយោបាយតូបនីយកម្ម និងសន្តិសុខតូបនីយកម្មហួសហេតុ ដែលនាំឱ្យមានការកើនឡើងនូវមន្ទិលសង្ស័យ និងឈានដល់បាត់បង់ទំនុកចិត្ត។ កត្តាចាំបាច់មួយទៀត គឺត្រូវរួមគ្នារក្សាតំបន់អាស៊ីអាគ្នេយ៍

ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងអាវុធប្រល័យលោកដទៃទៀត ដើម្បីធានានូវសន្តិសុខ ស្ថិរភាព និងសុខដុមនីយកម្មក្នុងតំបន់។ ការដោះស្រាយទំនាស់ត្រូវតែប្រកាន់យកការអត់ធ្មត់ ដោយសន្តិវិធី ផ្អែកលើច្បាប់អន្តរជាតិ តាមរយៈមធ្យោបាយការទូត និងគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។

# ការបត់បែននៅក្នុងយុទ្ធសាស្ត្រការពារជាតិ

## យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងតួនាទីរបស់កងយោធពលខេមរភូមិន្ទ

ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយការពារជាតិ ពឹងផ្អែកជាចម្បងលើការផ្ទៀងផ្ទាត់ និងការបន្សុីគ្នារវាងគោលនយោបាយការពារជាតិជាមួយនឹងការបត់បែនជាក់ស្តែងនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងវិស័យការពារជាតិ។ អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលអាណត្តិទី៧ និងប្រតិបត្តិតាមអនុសាសន៍របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** យើងត្រូវពិនិត្យឡើងវិញនូវតួនាទីរបស់កងយោធពលខេមរភូមិន្ទនៅក្នុងបរិបទថ្មី។

កងយោធពលខេមរភូមិន្ទគឺជាតួអង្គនាំមុខដ៏សំខាន់ ក្នុងការចូលរួមធានាឱ្យបាននូវបរិយាកាសប្រកបដោយសុខសន្តិភាពដើម្បីគាំទ្រការអភិវឌ្ឍជាតិប្រកបដោយចីរភាព។ តួនាទីបួនយ៉ាងរបស់កងយោធពលខេមរភូមិន្ទត្រូវបានកំណត់ចាប់តាំងពីឆ្នាំ២០០០មក រួមមាន៖ (១) ការពារបូរណភាពទឹកដី និងអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា (២) ពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម (៣) រួមចំណែកនៅក្នុងការអភិវឌ្ឍជាតិ និង (៤) លើកស្ទួយកិច្ចសហប្រតិបត្តិការយោធាជាមួយអន្តរជាតិ។ ដូច្នេះ បើផ្ទៀងផ្ទាត់ជាមួយនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងការវិវត្តនៃសភាពការណ៍ទាំងក្នុង និងក្រៅប្រទេស កងយោធពលខេមរភូមិន្ទចាំបាច់ត្រូវប្រកាន់យកនូវតួនាទីដ៏មានសារៈសំខាន់ និងចាំបាច់បំផុតទាំងនេះ ដោយមានភាពបត់បែន និងសង្គតិភាព ដើម្បីឆ្លើយតបទៅនឹងស្ថានភាពសន្តិសុខទំហំនៃការគំរាមកំហែង និងតម្រូវការចាំបាច់នៅក្នុងការការពារដល់ផលប្រយោជន៍ជាតិ។

## កិច្ចការពារព្រំដែន

យុទ្ធសាស្ត្រចម្បងមួយក្នុងកិច្ចការពារជាតិគឺការពង្រឹងខឿនការពារជាតិ ដែលសំដៅលើការការពារបូរណភាពទឹកដី អធិបតេយ្យ និងផល

ប្រយោជន៍ជាតិ។ ហេតុដូចនេះ ការអភិវឌ្ឍជាលំដាប់នូវសមត្ថភាពនៃកិច្ចការពារព្រំដែនគោក ទឹក និងអាកាស គឺជាអាទិភាពសំខាន់មួយ ដែលទាមទារអោយមានការយកចិត្តថែមទៀត សម្រាប់ជាផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម និងរយៈពេលវែង។ ការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង និងតួនាទីភារកិច្ចរបស់បណ្តាកងកម្លាំងដែលឈរជើងនៅតាមបណ្តោយព្រំដែន គឺជាផែនការយុទ្ធសាស្ត្រដែលគួរអនុវត្ត ដើម្បីធានាគុណភាព និងប្រសិទ្ធភាពក្នុងការឆ្លើយតបនឹងគ្រប់សភាពការណ៍ដែលជះឥទ្ធិពលដល់សន្តិសុខ ស្ថិរភាពព្រំដែនអោយទាន់ពេលវេលា។ ដូច្នេះ រាល់កងកម្លាំងតំបន់ដែលកំពុងឈរជើងនៅតាមបណ្តោយព្រំដែនគួរត្រូវបានប្រគល់តួនាទីភារកិច្ចលើកិច្ចការពារព្រំដែន ដោយរក្សាកងកម្លាំងទ័ពស្រួចជាកម្លាំងអន្តរាគមន៍ក្នុងសភាពការណ៍ចាំបាច់។

ទន្ទឹមនេះ ត្រូវពង្រឹងសមត្ថភាពរបស់កងកម្លាំងការពារព្រំដែនតាមរយៈការហ្វឹកហ្វឺនរៀនសូត្រ និងការបំពាក់សព្វាវុធយុទ្ធោបករណ៍ឱ្យស្រប តាមស្ថានភាពសន្តិសុខ និងការវិវត្តនៃបច្ចេកវិទ្យាយោធា។ លើសពីនេះទៀត ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់កម្លាំង យើងគួរបែងចែក និងចល័តកម្លាំងនៅក្នុងកងឯកភាពនីមួយៗសម្រាប់ការឈរជើង (Deploy) ការហ្វឹកហ្វឺន (Train) និងទទួលបានការសម្រាក (Refresh) ។ ជាមួយនេះដែរ គួរយកចិត្តទុកដាក់លើការលើកកម្រិតសមត្ថភាពនៃការឃ្លាំមើលលើតំបន់ព្រំដែន និងលើផ្ទៃសមុទ្រ ដោយប្រើប្រាស់ឧបករណ៍ទំនើបទាន់សម័យដូចជាដ្រូន ជាដើម បន្ថែមពីលើការធ្វើល្បាត ដែលជាជំនួយដ៏សំខាន់នៅក្នុងការប្រមូលព័ត៌មាន និងឆ្លើយតបទៅនឹងសភាពការណ៍ បានទាន់ពេលវេលា។

## ទំនើបកម្មយោធា និងការគ្រប់គ្រងកម្លាំង

ការធ្វើទំនើបកម្មមូលដ្ឋានសមុទ្ររាមរបស់កងទ័ពជើងទឹក បានប្រព្រឹត្តទៅជាលំដាប់លំដោយស្របតាមគោលដៅនៃការពង្រឹងសមត្ថភាពកងទ័ពជើងទឹក សម្រាប់កិច្ចការពារបូរណភាព និងអធិបតេយ្យដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងរួមចំណែកក្នុងការលើកស្ទួយកិច្ចសហប្រតិបត្តិការសន្តិសុខនៅក្នុងតំបន់។ ទោះបីជាមានការចោទប្រកាន់ឥតឈប់ឈរមកលើសិទ្ធិ និងអធិបតេយ្យរបស់កម្ពុជាក៏ដោយ ក៏យើងនៅតែមាន

គោលជំហររឹងមាំនៅក្នុងការគោរពសិទ្ធិ និងផលប្រយោជន៍អ្នកដទៃ និងគ្មានមហិច្ឆតាបង្កការគំរាមកំហែងដល់ប្រទេស ឬតំបន់ណាមួយនោះឡើយ។ បន្ទាប់ពីដំណើរការធ្វើទំនើបកម្មមូលដ្ឋានរាមចប់សព្វគ្រប់ កម្ពុជានឹងមានសមត្ថភាពកើនឡើងមួយកម្រិតទៀត ក្នុងការគ្រប់គ្រងសភាពការណ៍ក្នុងដែនសមុទ្រកម្ពុជា ដើម្បីបង្ការ ការពារ ទប់ស្កាត់ និងឆ្លើយតបទៅនឹងឧប្បទ្ទវហេតុនានាបានទាន់ពេលវេលា និងមានប្រសិទ្ធភាព។ ទន្ទឹមនេះ កម្ពុជានឹងមានឱកាសកាន់តែទូលំទូលាយនៅក្នុងកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខលម្ហសមុទ្រជាមួយដៃគូអន្តរជាតិ និងក្នុងក្របខណ្ឌតំបន់ផងដែរ។ តែទោះជាដូច្នេះក្តី ការប្រើប្រាស់សមត្ថភាពទាំងអស់នេះ គួរអនុវត្តឱ្យស្របតាមគោលនយោបាយជាតិ និងយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខលម្ហសមុទ្រជាចាំបាច់។

សង្គ្រាមនៅអ៊ុយក្រែន និងនៅមជ្ឈឹមបូព៌ា ព្រមទាំងការអភិវឌ្ឍសមត្ថភាពកងទ័ពនៅតាមបណ្តាប្រទេសក្នុងតំបន់ បានបង្ហាញយ៉ាងច្បាស់អំពីទម្រង់ថ្មីនៃសង្គ្រាម។ ជាក់ស្តែង នៅស្ទើរគ្រប់សមរភូមិ ការវាយប្រហារពីអាកាស និងពីចម្ងាយនៅលើដីគោក បានក្លាយជាយុទ្ធវិធីដ៏ពេញនិយម។ កងយោធពលខេមរភូមិន្ទ គួរពិចារណាលើទិដ្ឋភាពទាំងនេះ ដោយពង្រឹងសមត្ថភាពលើការការពារ ប្រព័ន្ធការពារអាកាស សង្គ្រាមដ្រូន (Drone Warfare) និងសមត្ថភាពវាយប្រហាររយៈឆ្ងាយ (Long-Range Strike) ក្នុងដែនអធិបតេយ្យភាពកម្ពុជា។ យើងក៏គួរពង្រឹងសមត្ថភាពផ្នែកឧស្សាហកម្មយោធាឱ្យបានរឹងប៉ឹង ទាំងបរិមាណ និងគុណភាព ដើម្បីធានាបាននូវនិរន្តរភាពក្នុងការហ្វឹកហ្វឺនបណ្តុះបណ្តាល និងកិច្ចប្រតិបត្តិការ ដែលជាវិស័យគន្លឹះសម្រាប់យុទ្ធសាស្ត្រនេះ។ យើងពិតជាមានការលំបាក នៅក្នុងកិច្ចការនេះនៅគ្រាដំបូង ប៉ុន្តែក៏អាចស្វែងរកដៃគូដែលទុកចិត្តបានសម្រាប់ជួយកសាងសមត្ថភាពផ្នែកលើសិទ្ធិ និងកាតព្វកិច្ចក្នុងនាមជារដ្ឋអធិបតេយ្យមួយ។ ជាមួយនេះដែរ យើងត្រូវបង្កើនការយកចិត្តទុកដាក់លើការការពារកម្លាំង (Force Protection) នៅក្នុងកាលៈទេសៈ ដែលមានសម្ពាធខ្លាំងក្នុងសមរភូមិ ផ្តល់ការគាំទ្របានទាន់ពេលវេលា មានកម្លាំងជំនួយគ្រប់គ្រាន់ ការគាំពារផ្នែកសុខមាលភាព ព្រមទាំងវិធានការផ្សេងៗទៀត។

ការកសាងសមត្ថភាពកងទ័ពនាសម័យទំនើប ផ្តោតសំខាន់លើសមត្ថភាពប្រតិបត្តិការកម្លាំងចម្រុះ (Joint Operational Capability)។ កង

យោធពលខេមរភូមិន្ទគួរយកចិត្តទុកដាក់បន្ថែមទៀតលើការកសាងសមត្ថភាពផ្នែកអន្តរប្រតិបត្តិការ (Interoperability) នៅក្នុងការប្រើប្រាស់កម្លាំង និងសម្ភារសឹកតាមរយៈការហ្វឹកហ្វឺន ឬការធ្វើសមយុទ្ធរួមគ្នារវាងប្រភេទទ័ព និងកងឯកភាពជំនាញផ្សេងៗ។ ម្យ៉ាងទៀត សមត្ថភាពប្រតិបត្តិការកម្លាំងចម្រុះ និងអន្តរប្រតិបត្តិការ នឹងជួយសម្រួលដល់កិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិ ផងដែរ។

កងយោធពលខេមរភូមិន្ទ តែងបំពេញភារកិច្ចនាំមុខនៅក្នុងប្រតិបត្តិការជួយសង្គ្រោះនៅពេលមានគ្រោះមហន្តរាយផ្សេងៗ ជាពិសេសពេលមានទឹកជំនន់ ប្រកបដោយគុណសម្បត្តិយ៉ាងធំធេង។ តែទោះជាដូច្នេះក្តី យើងគួរមានការដកពិសោធន៍ពីកិច្ចប្រតិបត្តិការជួយសង្គ្រោះ នៅក្នុងឧប្បទ្ទវហេតុធ្លាក់ឧទ្ធម្ភាគចក្រ នៅតំបន់ជួរភ្នំក្រវ៉ាញ កាលពីខែកក្កដា ឆ្នាំ២០០៤។ ផ្អែកតាមបទពិសោធន៍នេះ ការបង្កើនសមត្ថភាព និងការត្រៀមលក្ខណៈផ្នែករុករក និងសង្គ្រោះ គឺជាតម្រូវកាចាំបាច់ ក្នុងនោះរួមមានសមត្ថភាពនៃការស្វែងរកទីតាំង (Locating) ល្បឿននៃការរុករកក្នុងពេលមានធាតុអាកាសមិនល្អ និងកិច្ចប្រតិបត្តិការពីអាកាស (Rappelling)។ សមត្ថភាពទាំងនេះរួមផ្សំជាមួយសមត្ថភាពផ្សេងៗទៀត ក៏អាចយកទៅប្រើប្រាស់នៅក្នុងការជួយសង្គ្រោះ ពេលមានឧប្បទ្ទវហេតុនៅលើនាវាដឹកអ្នកដំណើរធំៗ (Cruise Ship) និងការលិចធ្លាយ ឬកំពប់ប្រេងផងដែរ។

## សន្តិសុខព័ត៌មាន និងការប្រឆាំងអំពើភេរវកម្ម

សន្តិសុខព័ត៌មាន (Information Security) និងការប្រឆាំងអំពើភេរវកម្ម (Counter Terrorism) មានទំនាក់ទំនងគ្នាយ៉ាងស្អិតល្មួត។ សង្គ្រាមនៅមជ្ឈឹមបូព៌ាដែលកំពុងរីករាលដាល បានធ្វើឱ្យប្រទេសជាច្រើន កំពុងគិតគូអំពីវិធានការទប់ទល់នឹងលទ្ធភាពនៃអំពើភេរវកម្មនៅលើទឹកដីរបស់ខ្លួន ដែលជំរុញដោយគំនិតជ្រុលនិយម (Radicalisation) និងសតិជ្រុលនិយមដោយខ្លួនឯង (Self-Radicalisation)។ បណ្តាញភេរវករអន្តរជាតិ អាចនឹងប្រើប្រាស់រូបភាពនៃមហន្តរាយនៅហ្គាហ្សា សោកនាដកម្មរបស់ជនជាតិប៉ាឡេស្ទីនរាប់សែននាក់ ការរងគ្រោះរបស់ប្រជាជនលីបង់ និងអរិភាពនៅទីកន្លែងផ្សេងទៀត ដើម្បីអូសទាញសមានចិត្ត និងការគាំទ្រដល់សកម្មភាពភេរវកម្មជាអន្តរជាតិ

របស់គេ។ គោលដៅនៃការវាយប្រហារ អាចជាជនស៊ីវិល ស្ថានទូត និង ទ្រព្យសម្បត្តិ របស់បណ្តាប្រទេសជាគោលដៅមួយចំនួន។ ទោះបីជាលទ្ធភាព នៃការវាយប្រហារនៅមានតិចតួចក៏ដោយ កម្ពុជាចាំបាច់ត្រូវពង្រឹងវិធានា ការប្រឆាំងអំពើភេរវកម្ម ជាពិសេសនៅក្នុងផ្នែកព័ត៌មានសម្ងាត់ និងកិច្ច សហការជាមួយដៃគូសន្តិសុខបរទេស។ ការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ បែបញុះញង់ បង្កឱ្យមានចលាចលក្នុងរូបភាពលាក់មុខ ឬជ្រកក្រោមសេរីភាព នៃការបញ្ចេញមតិដែលឈានដល់ការធ្វើបដិវត្តន៍ពណ៌គ្រប់ទម្រង់ គឺជាការ គំរាមកំហែងដល់សន្តិភាព សន្តិសុខ ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់ សាធារណៈ និងភាពសុខដុមរមនារបស់ប្រជាពលរដ្ឋកម្ពុជា។ យើងត្រូវបង្កើន ការយកចិត្តទុកដាក់ថែមទៀត ចំពោះគ្រោះថ្នាក់នៃការផ្សារភ្ជាប់រវាងបទល្មើស ព័ត៌មានវិទ្យា និងអំពើភេរវកម្ម។

## សន្តិសុខសាយប័រ

ដោយសារការកើនឡើងជាលំដាប់នៃបរិបទសមរភូមិឌីជីថល និង តម្រូវការនៃសន្តិសុខសាយប័រ ភាពងាយរងគ្រោះដោយការវាយប្រហារ សាយប័រ មកលើប្រព័ន្ធបណ្តាញ និងហេដ្ឋារចនាសម្ព័ន្ធយោធា គឺជាការ គំរាមកំហែងដល់សន្តិសុខជាតិ។ កងយោធពលខេមរភូមិន្ទត្រូវបង្កើត យុទ្ធសាស្ត្រសន្តិសុខសាយប័រដ៏ទូលំទូលាយ ដែលជាការចាំបាច់សម្រាប់ ការពារព័ត៌មានយោធាដែលជាព័ត៌មានរសើប (Sensitive Military Information) ពង្រឹងការត្រៀមលក្ខណៈនៅក្នុងកិច្ចប្រតិបត្តិការ និងធានាបាននូវភាពធន់ សម្រាប់ប្រព័ន្ធសំខាន់ៗ។ ស្របតាមយុទ្ធសាស្ត្រការពារសន្តិសុខសាយប័រ (Defensive Cybersecurity Strategy) ដើម្បីធ្វើឱ្យបណ្តាញយោធាស្នូលមាន សុវត្ថិភាព វិធានការណ៍ C5ISR ដ៏រឹងមាំមួយ (ការដឹកនាំបញ្ជា ការគ្រប់គ្រង ទំនាក់ទំនង កុំព្យូទ័រ សាយប័រ ចារកម្ម ការឃ្លាំមើល និងឈ្លបយកការណ៍) ក៏ត្រូវមានការអភិវឌ្ឍ ដើម្បីឱ្យកងយោធពលខេមរភូមិន្ទអាចប្រមូលផ្តុំ និង វិភាគព័ត៌មានចារកម្មប្រកបដោយប្រសិទ្ធភាព អាចសម្របសម្រួលកិច្ច ប្រតិបត្តិការឆ្លងកាត់វិស័យ និងឆ្លើយតបយ៉ាងមានប្រសិទ្ធភាពចំពោះការគំរាម កំហែងដែលកំពុង ឬអាចកើតមានឡើង។ តាមរយៈការផ្តល់អាទិភាព

ចំពោះសមត្ថភាពទាំងនេះ យើងអាចពង្រឹងសមត្ថភាពយោធាក្នុងការការពារផលប្រយោជន៍ជាតិ និងរួមចំណែកដល់សន្តិសុខក្នុងតំបន់។

## សន្តិសុខសេដ្ឋកិច្ច

ខណៈដែលសកលលោកកំពុងរងផលប៉ះពាល់កាន់តែខ្លាំងឡើងពីសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន នៅមជ្ឈឹមបូពា ព្រមទាំងការប្រណាំងប្រជែងផ្នែកសមត្ថភាពយោធានៅក្នុងតំបន់ សន្តិសុខសេដ្ឋកិច្ចកំពុងក្លាយជាប្រធានបទចម្បងមួយ។ ក្រៅពីការព្រួយបារម្ភអំពីខ្សែសង្វាក់នៃការផ្គត់ផ្គង់ (Supply Chain) ដែលជំរុញឱ្យកំណើនសេដ្ឋកិច្ចសកលលោកមានការថយចុះ ទំនិញឡើងថ្លៃ អាជីវកម្មជាប់គាំង...ល យើងគួរមានការគិតគូរអំពីទំនាក់ទំនងរវាងសន្តិសុខសេដ្ឋកិច្ច និងសកម្មភាពនៃអំពើភេរវកម្មលើគោលដៅសំខាន់ៗមួយចំនួនដូចជា ប្រភពទឹកស្អាត ទំនប់វារីអគ្គិសនី និងស្ថានីយអគ្គិសនី កន្លែងស្តុកប្រេងឥន្ធនៈ តំបន់ទេសចរណ៍ រោងចក្រផលិតសារធាតុគីមី ។ល។ ដូច្នេះ គួរមានវិធានការក្នុងការគ្រប់គ្រងផ្នែកសន្តិសុខសេដ្ឋកិច្ចឱ្យបានហ្មត់ចត់ថែមទៀត។ ការបោកបញ្ឆោតតាមអនឡាញដែលកំពុងរីករាលដាលនៅតាមប្រទេសមួយចំនួន រួមទាំងនៅប្រទេសកម្ពុជាផងដែរ គឺជាការគំរាមកំហែងមួយដែលពាក់ព័ន្ធនឹងសន្តិសុខព័ត៌មានវិទ្យា។ ក្រៅពីផលប៉ះពាល់ទៅលើសេដ្ឋកិច្ច សកម្មភាពទាំងនេះ កំពុងធ្វើឱ្យបាត់បង់ទំនុកចិត្តមកលើរាជរដ្ឋាភិបាលកម្ពុជា លើការវិនិយោគ និងវិស័យទេសចរណ៍។

## ការចូលរួមក្នុងកិច្ចការអភិវឌ្ឍជាតិ

កងយោធពលខេមរភូមិន្ទមានសមត្ថភាពមួយចំនួនសម្រាប់នាំមុខ និងចូលរួមនៅក្នុងការងារសង្គម។ ក្រៅពីការរួមចំណែកក្នុងការធានាសន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម កងយោធពលខេមរភូមិន្ទ គឺជាកម្លាំងនាំមុខក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនៅតាមតំបន់ដាច់ស្រយាល កសាងផ្លូវក្រវ៉ាត់ព្រំដែន ប្រតិបត្តិការសង្គ្រោះគ្រោះមហន្តរាយ និងចូលរួមសហការយ៉ាងសកម្មលើការងារបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ។ ដូច្នេះ កងយោធពលខេមរភូមិន្ទគួរបង្កើនសមត្ថភាពជំនាញ និងសម្ភារបច្ចេកទេសទំនើបទាន់

សម័យសម្រាប់បំពេញភារកិច្ចឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។ ម្យ៉ាងទៀត យើងគួរអភិវឌ្ឍកងកម្លាំងដែលមានភារកិច្ចក្នុងប្រតិបត្តិការជំនួយមនុស្សធម៌ និងសង្គ្រោះគ្រោះមហន្តរាយ (HADR) និងប្រតិបត្តិការរុករក និងសង្គ្រោះ (SAR)។

## កិច្ចសហប្រតិបត្តិការយោធាអន្តរជាតិ

គោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៧ ផ្តល់អាទិភាពទៅលើការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយឈរលើស្មារតីមិត្តភាព សមភាព ការយោគយល់គ្នា និងការគោរពផលប្រយោជន៍គ្នាទៅវិញទៅមក។ សម្រាប់វិស័យការពារជាតិ និងសន្តិសុខ ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាងគឺជាគន្លឹះនៅក្នុងការថែរក្សាសន្តិភាព ស្ថិរភាព ជំរុញការអភិវឌ្ឍ និងការរស់នៅប្រកបដោយភាពសុខដុមរមនារបស់ប្រជាពលរដ្ឋនៅតាមតំបន់ព្រំដែន។ កម្ពុជាផ្តល់តម្លៃខ្ពស់ចំពោះតួនាទីរបស់យន្តការទ្វេភាគី និងពហុភាគី ដែលមានស្រាប់ ដែលជាវេទិកាចាំបាច់សម្រាប់កិច្ចសន្ទនា និងផ្លាស់ប្តូរព័ត៌មានដើម្បីរក្សានិរន្តរភាពនៃទំនាក់ទំនងល្អ។

កម្ពុជារក្សាគោលជំហរម៉ឺងម៉ាត់ ក្នុងកិច្ចសហប្រតិបត្តិការលើវិស័យការពារជាតិ ជាមួយគ្រប់បណ្តាប្រទេសទាំងអស់ ដោយគោរពតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ជាតិ និងច្បាប់អន្តរជាតិទាំងឡាយ ដែលបម្រើ និងការពារអធិបតេយ្យ ឯករាជ្យភាព និងអព្យាក្រឹតភាពរបស់កម្ពុជា។ ក្នុងន័យនេះ រាល់កិច្ចសហប្រតិបត្តិការយោធានានា នឹងត្រូវស្ថិតក្នុងរូបភាពមិនប្រកាន់បក្សសម្ព័ន្ធ តែស្ថិតក្នុងក្របខណ្ឌភាពជាដៃគូតាមលំដាប់ជាដរាប។ យើងប្រកាន់ខ្ជាប់នូវគោលជំហររក្សាតុល្យភាពនៃកិច្ចសហប្រតិបត្តិការជាមួយប្រទេសមហាអំណាច និងបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី និងក្នុងក្របខណ្ឌតំបន់ឱ្យកាន់តែល្អប្រសើរថែមទៀត។ ទន្ទឹមនេះ កងយោធពលខេមរភូមិន្ទ នឹងបន្តយកចិត្តទុកដាក់នៅក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកអនុវត្តច្បាប់ ជាពិសេសនៅក្នុងវិស័យសន្តិសុខលម្ហសមុទ្រជាមួយស្ថាប័នអនុវត្តច្បាប់នៃបណ្តាប្រទេសក្នុងគោលបំណងចូលរួមថែរក្សាសន្តិសុខ ស្ថិរភាពលម្ហសមុទ្រ។

## ប្រតិបត្តិការរក្សាសន្តិភាព

ពីខាងដើម យើងបានធ្វើការវាយតម្លៃលើអនាគតនៃបេសកកម្មរក្សាសន្តិភាពនៅក្រោមឆ័ត្រអង្គការសហប្រជាជាតិ។ ទោះបីជាការងារនេះ ក្នុងពេលបច្ចុប្បន្ន កំពុងជួបប្រទះនឹងភាពប្រឈមមួយចំនួនក៏ដោយ យើងរំពឹងថាបេសកកម្មរក្សាសន្តិភាពនៅតាមប្រទេសដែលកំពុងមានអសន្តិសុខនឹងនៅតែជាតម្រូវការចាំបាច់ដដែល។ យើងជឿជាក់ថា បណ្តាប្រទេសដែលបានបដិសេធជាបណ្តោះអាសន្ន នូវតួនាទីរបស់បេសកកម្មរក្សាសន្តិភាពអង្គការសហប្រជាជាតិ នឹងផ្លាស់ប្តូរឥរិយាបទ នាពេលអនាគត។ ដូច្នេះកងយោធពលខេមរភូមិន្ទគួរបន្តពង្រឹង និងបង្កើនសមត្ថភាពសម្រាប់បេសកកម្មរក្សាសន្តិភាពរបស់ខ្លួននៅក្នុងវិស័យជាអាទិភាពបន្ថែមទៀត ជាពិសេសការបង្កើនតួនាទីរបស់ស្ត្រី សមត្ថភាពផ្នែកសង្គ្រោះគ្រោះមហន្តរាយ មន្ទីរពេទ្យកម្រិត២... ។ល។ ទន្ទឹមនេះ យើងក៏ត្រូវត្រៀមលក្ខណៈសម្រាប់ការចូលរួមណាមួយ ដែលអាចធ្វើបាន ក្រោយពីសង្គ្រាម ឬជម្លោះប្រដាប់អាវុធនៅតាមតំបន់នានានៃសកលលោក ត្រូវបានបញ្ចប់។

# អាទិភាពនៅក្នុងកំណែទម្រង់យោធា

កំណែទម្រង់យោធាគឺជាអាទិភាពមួយ ក្នុងចំណោមអាទិភាពទាំងបួននៃគោលនយោបាយការពារជាតិ ដែលត្រូវបន្តធ្វើនៅក្នុងគោលដៅនៃអាជីពភាវូបនីយកម្មកងយោធពលខេមរភូមិន្ទ។ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ សំដៅធ្វើឱ្យមានប្រសិទ្ធភាពក្នុងការកែសម្រួលរចនាសម្ព័ន្ធ ការបណ្តុះបណ្តាលធនធានមនុស្ស និងការគ្រប់គ្រងបុគ្គលិក។

## វិសោធនកម្មច្បាប់របស់កងយោធពលខេមភូមិន្ទ

ការធ្វើវិសោធនកម្មច្បាប់របស់កងយោធពលខេមរភូមិន្ទ ជាពិសេសច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ គឺជាកត្តាចម្បង និងជាអាទិភាពចាំបាច់ ក្នុងដំណើរការកំណែទម្រង់ទូទាំងកងយោធពលខេមភូមិន្ទ ដើម្បីរួមចំណែកអនុវត្តគោលនយោយការពារជាតិឱ្យមានប្រសិទ្ធភាពខ្ពស់។

## រចនាសម្ព័ន្ធកងទ័ព

ការងារចំពោះមុខនៅក្នុងការកែសម្រួលរចនាសម្ព័ន្ធកងទ័ព គឺការកាត់បន្ថយនូវការិយាធិបតេយ្យ និងកែសម្រួលស្ថាប័នដែលមានតួនាទី និងភារកិច្ចត្រួតលើគ្នា។ សម្រាប់កងឯកភាពប្រយុទ្ធ ត្រូវរក្សារចនាសម្ព័ន្ធដែលមានស្រាប់ ដោយពង្រឹងនូវបរិមាណ គុណភាព តួនាទីភារកិច្ច ទំនើបកម្មយុទ្ធោបករណ៍ និងគ្រឿងបំពាក់សម្ភារសឹកអោយបានពេញលេញ។

## កាតព្វកិច្ចយោធា

ការអនុវត្តកាតព្វកិច្ចយោធាគឺជាការចាំបាច់ ក្នុងការរក្សានិរន្តរភាពនៃកម្លាំង ជាប្រភពនៃកម្លាំងបម្រុង និងការពង្រឹងស្មារតីក្នុងកាតព្វកិច្ចការពារ

និងបម្រើជាតិរបស់ប្រជាជនកម្ពុជាគ្រប់រូប។ ច្បាប់ស្តីពីកាតព្វកិច្ចយោធាដែលចូលជាធរមានតាំងពីឆ្នាំ២០០៦ មិនទាន់ត្រូវបានអនុវត្តនៅឡើយ។ ច្បាប់នេះ ចាំបាច់ត្រូវធ្វើវិសោធនកម្ម ដើម្បីឱ្យកាតព្វកិច្ចយោធាត្រូវបានអនុវត្តទៀងទាត់ ទោះក្នុងទម្រង់ ទំហំ និងកាលៈទេសៈណាមួយក៏ដោយ។ កាតព្វកិច្ចយោធា នឹងផ្តល់ជាប្រភពសម្រាប់ការរៀបចំទ័ពបម្រុងដែលមានគុណភាព និងជាជំនួយដ៏សំខាន់នៅក្នុងការកាត់បន្ថយចំនួនទ័ពសកម្ម ព្រមទាំងជួយសន្សំថវិកាជាតិផងដែរ។

## ការហ្វឹកហ្វឺន

គុណភាពនៃការហ្វឹកហ្វឺន និងបណ្តុះបណ្តាលធនធានមនុស្សគ្រប់កម្រិត ត្រូវទទួលបានការយកចិត្តទុកដាក់បន្ថែមទៀត។ ស្ថាប័នដែលផ្តល់ការហ្វឹកហ្វឺនអាជីព (Professional Military Education) ចាំបាច់ត្រូវធ្វើទំនើបកម្មកម្មវិធីសិក្សា ដើម្បីលើកកម្រិតចំណេះដឹងរបស់កម្មសិក្សាការី និងឈានទៅរកការផ្លាស់ប្តូរកម្មសិក្សាការីជាមួយនឹងបរទេស។ ទន្ទឹមនឹងនេះ សមត្ថភាពរបស់យោធាចារ្យ ចាំបាច់ត្រូវមានការលើកកម្រិត។ ការអញ្ជើញអ្នកជំនាញ ឬអ្នកឯកទេសពីខាងក្រៅ ឱ្យមកជួយផ្តល់មេរៀន គឺជាជម្រើសដ៏ប្រសើរមួយ។ នាយទាហានដែលបញ្ចប់ការសិក្សាវគ្គយោធិនអាជីព គួរត្រូវបានលើកទឹកចិត្តឱ្យមកជួយចែករំលែកចំណេះដឹងផងដែរ។ លើសពីនេះ ស្វយ័តភាពរបស់សកលវិទ្យាល័យការពារជាតិ ក៏គួរមានការពិចារណា ក្នុងគោលដៅបង្កើនគុណភាពអប់រំឱ្យស្មើនឹងសកលវិទ្យាល័យនានា និងដើម្បីរកចំណូលតាមបែបធុរកិច្ច។

## ផែនការយុទ្ធសាស្ត្រ និងធនធានការពារជាតិ

ជាការពិត ជោគជ័យនៃការអនុវត្តគោលនយោបាយការពារជាតិ ពឹងផ្អែកមួយផ្នែកធំលើការរៀបចំផែនការយុទ្ធសាស្ត្របានគ្រប់ជ្រុងជ្រោយ។ ផែនការយុទ្ធសាស្ត្រ ត្រូវមានគោលដៅ (End) ច្បាស់លាស់ មានជម្រើស

វិធានការអនុវត្តបានល្អ (Way) និងមធ្យោបាយ (Mean) គ្រប់គ្រាន់។ ដូច្នេះ ការឆ្លើយតបគ្នាទៅវិញទៅមករវាងផែនការយុទ្ធសាស្ត្រ ជាមួយនឹងការគ្រប់គ្រងធនធានការពារជាតិ គឺជាគន្លឹះនៅក្នុងការសម្រេចគោលដៅជាស្ថាពរ។ ដើម្បីគាំទ្រដល់ផែនការយុទ្ធសាស្ត្រដែលបានដាក់ចេញ ក្រសួងការពារជាតិត្រូវការកញ្ចប់ថវិកាការពារជាតិប្រចាំឆ្នាំប្រហាក់ប្រហែល២.៧% នៃផលិតផលសរុបក្នុងស្រុកប្រចាំឆ្នាំ (ផ.ស.ស) ចាប់ពីឆ្នាំ២០២៦ ដល់ឆ្នាំ ២០៣០។

## ឧស្សាហកម្មការពារជាតិ

ឧស្សាហកម្មការពារជាតិ មានសារៈសំខាន់ណាស់ដើម្បីលើកកម្ពស់ប្រៀបការពារជាតិ ដោយផ្តោតលើទំនើបកម្មបច្ចេកវិទ្យា និងនវានុវត្តន៍យោធា ដើម្បីផលិតធានាជូនទៅតាមផែនការសេចក្តីត្រូវការរបស់កងយោធពលខេមរភូមិន្ទ និងការធ្វើពាណិជ្ជកម្ម និងវិនិយោគក្នុងវិស័យការពារជាតិ។

## ប្រវត្តិសាស្ត្រយោធា

បើសិក្សាឱ្យបានដិតដល់ វិស័យប្រវត្តិសាស្ត្រយោធាគឺជាប្រភពដ៏សំខាន់មួយ នៅក្នុងការកសាង និងបណ្តុះបណ្តាលធនធានមនុស្ស។ ជាងនេះទៅទៀត ប្រវត្តិសាស្ត្រយោធា ផ្សាភ្ជាប់ជានិច្ចជាមួយនឹងការកសាងគោលនយោបាយយុទ្ធសាស្ត្រ។ ទោះបីជាវិស័យប្រវត្តិសាស្ត្រយោធាមានវិសាលភាពទូលំទូលាយក៏ដោយ ការខិតខំសិក្សា ស្រាវជ្រាវ ចងក្រងអំពីសង្គ្រាមទូទៅ (General Warfare) រចនាសម្ព័ន្ធកងទ័ព ការវិវត្តនៃកិច្ចការយោធា (Evolution of Military Affairs) និងការទូតផ្នែកយោធាអន្តរជាតិ (Military Diplomacy) នឹងផ្តល់ជាករណីសិក្សា (Case Study) ដ៏មានប្រយោជន៍សម្រាប់វិស័យហ្វឹកហ្វឺនយោធិនអាជីព និងការរៀបចំយុទ្ធសាស្ត្រយោធាផ្សេងៗ។

## ការអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រ

**សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារសំខាន់នៃកិច្ចការស្រាវជ្រាវយុទ្ធសាស្ត្រ។ ក្រសួងការពារជាតិ គួរកំណត់យកក្រុមការងារសៀវភៅសការពារជាតិ ជាយន្តការសម្រាប់កសាង និងអភិវឌ្ឍគោលនយោបាយការពារជាតិ ក្នុងលំដាប់យុទ្ធសាស្ត្រជាន់ខ្ពស់ (Grand Strategy)។ ដោយឡែក ស្ថាប័នផ្សេងទៀត ដែលមានការពាក់ព័ន្ធនឹងការងារស្រាវជ្រាវយុទ្ធសាស្ត្រ អាចបំពេញភារកិច្ចរបស់ខ្លួន ក្នុងលំដាប់យុទ្ធសាស្ត្រ (Strategic) និងលំដាប់យុទ្ធនាការ (Operational)។ ក្នុងន័យនេះដែរ សាកលវិទ្យាល័យការពារជាតិ អាចធ្វើកិច្ចការនេះ ក្នុងលក្ខណៈជាអ្នកផ្តល់គំនិត (Think Tank)។ ផលិតផលរបស់ក្រុមទាំងបីប្រភេទនេះ នឹងបំពេញឱ្យគ្នាទៅវិញទៅមក។ នេះមានន័យថា លំដាប់យុទ្ធសាស្ត្រ និងលំដាប់ផ្តល់គំនិត អាចធ្វើការងាររបស់ខ្លួន ដោយយកយុទ្ធសាស្ត្រជាន់ខ្ពស់ជាមូលដ្ឋាន រីឯការអភិវឌ្ឍយុទ្ធសាស្ត្រជាន់ខ្ពស់ ក៏ត្រូវការធាតុចូលជាចាំបាច់ ពីលំដាប់យុទ្ធសាស្ត្រ និងលំដាប់ផ្តល់គំនិតវិញដែរ។

# ANALYSES

# STRATEGIC ASSESSMENTS

# AND RECOMMENDATIONS

**from the Defence White Paper Working Group**

**December 2024**

## Preface

The 2022 Defence White Paper of the Kingdom of Cambodia showcases the Royal Government's defence policy and strategy towards 2030. This policy outlines four defence objectives and strategic priorities: border protection, internal security, military reform, and international cooperation. Additionally, the 2022 Defence White Paper offers crucial recommendations for promoting the effective implementation of defence policy.

However, the constant evolution of the global and regional security landscape, along with the flexibility of the initial phase of the Royal Government's Pentagonal strategy, continuously influences national defence policy and strategy.

The purposes of the "Defence Strategic Update" are to:

- Promote research, analysis, evaluation, and policy development capabilities amongst the next generation of officers and strategists.

- Strategically analyse, evaluate, and provide update on security and defence situations.

- Provide essential recommendations to support senior officials' leadership and decision-making.

- Offer necessary inputs for reviews or policymaking within the defence sector.

This Defence Strategic Update does not reflect changes in policy or a review within the defence sector. Instead, it is a product of analyses, assessments, and recommendations based on recent developments within Cambodia, the region, and the world, from the Strategic Policy Group of the Defence White Paper Working Group. Thus, the Defence White Paper and the Defence Strategic Review remain the primary defence policy document or flexibility of defence policy, respectively. The second Defence Strategic Update will be published at the end of 2026 and will potentially become an official document from the Ministry of National Defence.

**Defence White Paper Working Group**

## Introduction

